# លក្ខន្តិកៈ

# អង្គការជនជាតិដើមភាគតិចកម្ពុជា

<u>បុព្វកថា</u>

ជនជាតិដើមភាគតិចនៅកម្ពុជា បាន និងកំពុងរស់នៅជាសហគមន៍ នៅក្នុងទឹកដីរបស់ខ្លួនតាំងពីដូនតារាប់ជំនាន់មកហើយរហូតមកដល់បច្ចុប្បន្ន ។ ពីរបើទសវត្សមុន សហគមន៍ជនជាតិដើមភាគតិចរបស់យើងមិនដែលមានវិវាទនឹងគ្នាដោយសារដីធ្លី និងធនធានធម្មជាតិសោះឡើយ ។ ពួកគាត់រស់នៅយ៉ាងសុខសាន្ត ជាសហគមន៍មានវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់ខ្លួនរៀងៗខ្លួន ។ ការវិវត្តនៃសេដ្ឋកិច្ចកម្ពុជា និងសកលលោកបាន និងកំពុងដាក់សហគមន៍ជនជាតិដើមភាគតិចរបស់យើងនៅក្នុងស្ថានភាពងាយរងគ្រោះបំផុត នៅលើទឹកដីរបស់ខ្លួនដែលធ្លាប់ជាម្ចាស់ ។ ការបាត់បង់ភាពជាម្ចាស់លើដីធ្លី ព្រៃឈើ និងងធនធនាធម្មជាតិនាពេលថ្មីៗនេះ នៅស្ទើរគ្រប់ទីកន្លែងដែលមានវត្តមានជនជាតិដើមភាគតិចបានធ្វើឲ្យមានការបារម្មណ៍ជាខ្លាំង ។ កូនចៅជំនាន់ក្រោយត្រូវការទឹកដី ធនធានអត្តសញ្ញាណជាជនជាតិដើមភាគតិច ដែលអត្តសញ្ញាណជាជីវិតរបស់សហគមន៍ជនជាតិដើមភាគតិចផ្សាភ្ជាប់នឹងដីព្រៃឈើ ធនធានធម្មជាតិនៅក្នុងតំបន់របស់សហគមន៍រស់នៅ ។ ការគ្មានដី គ្មានព្រៃ គឺគ្មានអ្វីៗទាំងអស់សម្រាប់ការរស់នៅជាសហគមន៍មានអត្តសញ្ញាណរបស់ខ្លួននាបច្ចុប្បន្ន និងកូនចៅជំនាន់ក្រោយ ។ ចំណេះដឹង និងរបៀបរបបរស់នៅជាប្រពៃណី ទំនៀមទម្លាប់ បានរក្សាទុកយ៉ាងគង់វង្សនូវទឹកដី ព្រៃឈើ និងធនធានធម្មជាតិទាំងឡាយរហូតមកដល់ប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ដោយមានការព្រួយបារម្មណ៍ជាពន់ពេកចំពោះវាសនាអនាគតរបស់ជនជាតិដើមភាគតិចជំនាន់នេះ និងជំនាន់ក្រោយ ពិសេសឱកាសរួចចាកផុតពីភាពក្រីក្រ និងភាពជាម្ចាស់លើជីវិតរបស់ខ្លួនក្រុមគ្រួសារ និងសហគមន៍ទាំងមូល សមាជិកស្ថាបនិកបានផ្តួចផ្តើមបង្កើតអង្គការនេះឡើង ដោយដាក់ឈ្មោះថា "អង្គការជនជាតិដើមភាគតិចកម្ពុជា" ។

## ជំពូកទី ១

## អំពីឈ្មោះ អាសយដ្ឋាន អត្តសញ្ញាណ រូបសញ្ញា និងត្រា

ប្រការ១: អង្គការនេះមានឈ្មោះថា " អង្គការជនជាតិដើមភាគតិចកម្ពុជា " សរសេរជាអក្សរកាត់ថា អ.ជ.ក និងមានឈ្មោះជាភាសាអង់គ្លេសថា " Cambodia Indigenous Peoples Organization" សរសេរអក្សរកាត់ថា **"CIPO"**។

ប្រការ២: អង្គការជនជាតិដើមភាគតិចកម្ពុជា (អ.ជ.ក) មានទីស្នាក់ការកណ្តាលតាំងនៅរាជធានីភ្នំពេញ និងអាចផ្លាស់ប្តូរ ឬពង្រីកសាខានៅតាមបណ្តាខេត្តនានាតាមការសម្រេចដោយសំឡេងគាំទ្រ ២/៣ នៃគណៈគ្រប់គ្រងរបស់អង្គការ ។

ប្រការ៣: អ.ជ.ក គឺជាអង្គការអព្យាក្រិត មិនស្វែងរកចំណេញ មិនប្រកាន់ពូជសាសន៍ សាសនានិន្នាការនយោបាយ ពណ៌សម្បុរ មិនធ្វើសកម្មភាពបម្រើគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍នយោបាយរបស់គណបក្សនយោបាយឡើយ ។ អង្គការនេះបម្រើតែផលប្រយោជន៍សង្គម សាធារណៈ យកចិត្តទុកដាក់ជាពិសេសលើការធ្វើ

កិច្ចការនានាពាក់ពន្ធ័នឹងសហគមន៍ជនជាតិដើមភាគតិច ។

ប្រការ៤: រូបសញ្ញារបស់ អ.ជ.ក មានសណ្ឋានជាផ្ទះអណ្តើកជនជាតិព្នង ស្ថិតលើដីសហគមន៍ដែលមានដំណាំផ្សេងៗ និងព្រៃឈើ ធម្មជាតិ ដែលត្រូវបានរក្សា ការពារ និងគោរពយ៉ាងហ្មតចត់ ។

ត្រារបស់ អ.ជ.ក មានរាងជារង្វង់មូលពីជោន់ទំហំ៣៤ មម នៅកន្លះរង្វង់ផ្នែកខាងលើមានចារិកឈ្មោះអង្គការជាភាសាខ្មែរ នៅកន្លះរង្វង់ផ្នែកខាងក្រោមមានចារឹកឈ្មោះអង្គការជាភាសាអង់គ្លេស និងនៅចន្លោះអក្សរចារិកទាំងពីរមានរូបផ្កាចន្ទន៍អមសងខាង នៅក្នុងរង្វង់ផ្នែកខាងក្នុងមានរូបសញ្ញារបស់អង្គការ និងអក្សរកោត់ជាភាសាអង់គ្លេសថា " C.I.P.O " និងប្រើទឹកល័ក្តពណ៌ខៀវ ។

## ជំពូកទី ២

## អំពី គោលបំណង និងបេសកកម្ម

ប្រការ៥: អ.ជ.ក បង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ជីវភាព សុខុមាលភាព សង្គម វប្បធម៌ ប្រពៃណីរបស់សហគមន៍និងជនជាតិដើមភាគតិចនៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យមាននិរន្តរភាព និងជាសហគមន៍ជនជាតិដើមភាគតិចជាអចិន្ត្រៃយ៍ ។ ដើម្បីអាចសម្រេចបានគោលបំណងរបស់ខ្លួន អជក មានបេសកកម្មដូចខាងក្រោម :

១. បង្កើនចំណេះដឹង សមត្ថភាព ជំនាញវិជ្ជាជីវៈផ្សេងៗដល់ជនជាតិដើមភាគតិចពាក់ពន្ធ័ទៅនឹងប្រពៃណីទំនៀមទំលាប់ ដីធ្លីនិងសិទ្ធិសេរីភាពការទទួលខុសត្រូវដែលទាក់ទងនឹងច្បាប់ជាតិ អន្តរជាតិ គោលនយោបាយលិខិតបទដ្ឋានជាតិនានា ។

២.សិក្សាស្រាវជ្រាវ និងចងក្រងរាល់ឯកសារពាក់ព័ន្ធអត្តសញ្ញាណប្រពៃណីទំនៀមទំលាប់ល្អរបស់ជនជាតិដើមភាគតិច។

៣.រៀបចំចងក្រងសហគមន៍ជនជាតិដើមភាគតិចដើម្បីជានាសិទ្ធិសមូហភាព និងឯកជនរបស់សមាជិកសហគមន៍លើដីធ្លី ធនធានធម្មជាតិស្របតាមច្បាប់ និងគោលនយោបាយជាតិ ច្បាប់អន្តរជាតិ ប្រពៃណីទំនៀមទំលាប់ ។

៤.ផ្សព្វផ្សាយដល់សាធារណៈជនជាតិ និងអន្តរជាតិអំពីជនជាតិដើមភាគតិចនៅកម្ពុជា។

៥.ផ្តល់សេវាកម្ម និងជំនួយផ្នែកច្បាប់ដល់សហគមន៍ជនជាតិដើមភាគតិចជាលក្ខណៈសមូហភាព និងជាលក្ខណៈបុគ្គល ។

## ជំពូកទី ៣

## អំពីសមាជិកភាព និងការបាត់បង់សមាជិកភាព

ប្រការ ៦: សមាជិករបស់ អ.ជ.ក មានបីប្រភេទ:

សមាជិកស្ថាបនិក:

- គឺជាអ្នកទាំងឡាយណាដែលបានចូលរួមទាំងកម្លាំង និងថវិកាក្នុងការបង្កើត អ.ជ.ក មុនដំបូងបង្អស់។
- គឺជាអ្នកស្នើឲ្យមានសមាជិកក្រុមប្រឹក្សាភិបាល និងចាស់ទុំជនជាតិដើមភាគតិចលើកដំបូងបង្អស់។

- គឺជាអ្នកព្រាង និងអនុម័តលក្ខន្តិកៈរបស់ អ.ជ.ក លើកដំបូង។

សមាជិកពេញសិទ្ធិ:

- គឺជាជនទាំងឡាយណាដែលបានចូលជាសមាជិក បុគ្គលិក អ.ជ.ក ដោយយល់ព្រមចូលរួមក្នុងសកម្មភាពរបស់ អ.ជ.ក យ៉ាងសកម្មទៅតាមលក្ខខណ្ឌតម្រូវជាក់ស្តែង។

សមាជិកកិត្តិយសៈ

- គឺជាជនទាំងឡាយណាដែលចូលរួមជួយឧបត្ថម្ភជាសម្ភារ ថវិកា ឬ ផ្តល់គំនិតយោបល់ផ្សេងៗ ដែលនាំឲ្យមានការរីកចម្រើនដល់ អ.ជ.ក ។

ប្រការ៧: លក្ខខណ្ឌនៃការបាត់បង់សមាជិកភាព និងបុគ្គលិកភាពពី អ.ជ.ក មានដូចតទៅ:

-ទទួលមរណភាព

-ចប់កិច្ចសន្យាការងារ

-បានដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរជូននាយកប្រតិបត្តិឲ្យបាន១៥ថ្ងៃមុនថ្ងៃឈប់ពីការងារ

-មិនគោរព និងអនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់អង្គការ ហើយត្រូវបានបណ្តេញចេញដោយសេចក្តីសម្រេចដោយសំឡេងគាំទ្រ ៥០% + ១ នៃសមាជិកគណៈគ្រប់គ្រងរបស់អង្គការ

-ជាប់ពិរុទ្ធពីបទល្មើសណាមួយដែលមានសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា

-មានជំងឺវិកលចរិត ដែលមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យស្របច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ៨: ការសម្រេចជ្រើសរើសអ្នកមកជំនួសអ្នកដែលបានបាត់បង់សមាជិកភាព ឬបុគ្គលិកភាពដូចមានចែងក្នុងប្រការ៧ ជាសមត្ថកិច្ចរបស់គណៈគ្រប់គ្រង។

## ជំពូកទី ៤

## អំពីរចនាសម្ព័ន្ធគ្រប់គ្រង

ប្រការ៩: អ.ជ.ក មានរចនាសម្ព័ន្ធគ្រប់គ្រង និងដឹកនាំដូចខាងក្រោម:

- ក្រុមប្រឹក្សាភិបាល / ក្រុមចាស់ទុំជនជាតិដើមភាគតិច
- គណៈគ្រប់គ្រង ដែលមានសមាសភាពៈ នាយិកាឬនាយកប្រតិបត្តិ ប្រធានកម្មវិធី មន្រ្តីហិរញ្ញវត្ថុ មន្រ្តីរដ្ឋបាល ប្រធានផ្នែកនីមួយៗ
- បុគ្គលិក /សមាជិក ។

## ជំពូកទី ៥

## អំពីក្រុមប្រឹក្សាភិបាល

ប្រការ១០: ក្រុមប្រឹក្សាភិបាលជាស្ថាប័នកំពូលរបស់ អ.ជ.ក និងមានសមាជិកយ៉ាងតិចចំនួន៣រូប និងយ៉ាងច្រើនបំផុត៥រូប និងមានអាណត្តិ៤ឆ្នាំ ដែលនៅដំណាក់កាលដំបូងត្រូវបានជ្រើសតាំងឡើងតាមការស្នើសុំដោយក្រុម

ស្ថាបនិករបស់អង្គការចំពោះអ្នកដែលបានបំពេញតាមលក្ខខណ្ឌដូចប្រការ១២ នៃលក្ខន្តិកៈនេះ ។ នៅអាណត្តិជាបន្តបន្ទាប់ក្រុមប្រឹក្សាភិបាលត្រូវជ្រើសតាំងឡើងតាមរយៈការពិគ្រោះ ពិភាក្សាសម្រេចរវៀងសមាជិកក្រុមប្រឹក្សាភិបាលចាស់ ក្រុមចាស់ទុំ និងគណៈគ្រប់គ្រង និងតាមការឯកភាពដោយសំឡេងគាំទ្រ៥០% + ១ ។

ប្រការ១១: តួនាទីក្រុមប្រឹក្សាភិបាល

- ផ្តល់ប្រឹក្សាយោបល់ ទៅលើផ្នែកគោលនយោបាយធំៗ ដើម្បីធានាដល់ការអនុវត្ត ដែលស្របតាមទស្សនវិស័យ និងបេសកម្មរបស់អង្គការ
- ជាអ្នកដែលធ្វើការដោយស្ម័គ្រចិត្ត មិនទទួលបានប្រាក់ខែ
- អនុម័តលើគោលនយោបាយហិរញ្ញវត្ថុ ធនធានមនុស្ស និងបទបញ្ជាផ្ទៃក្នុងរបស់ អ.ជ.ក
- រៀបចំរចនាសម្ព័ន្ធដឹកនាំរបស់ អ.ជ.ក
- ចូលរួមប្រឹក្សាយោបល់ និងសម្រេចចិត្តក្នុងការកែប្រែ ឬរំលាយ អ.ជ.ក ដោយមានការពិគ្រោះយោបល់ជាមួយគណៈគ្រប់គ្រង
- ជួយគាំទ្រ និងទំនាក់ទំនងស្វែងរកថវិកាជាមួយម្ចាស់ជំនួយដើម្បីទ្រទ្រង់ដល់សកម្មភាព អ.ជ.ក
- ដើរតួនាទីជាអាជ្ញាកណ្តាលសម្រាប់ដោះស្រាយនៅពេលមានវិវាទផ្ទៃក្នុងធំៗនៅក្នុង អ.ជ.ក ដែលហួសពីដែនសមត្ថកិច្ចរបស់គណៈគ្រប់គ្រង
- ជ្រើសរើស តែងតាំង ដាក់វិន័យ ដកហូតនាយក ឬនាយិកាប្រតិបត្តិ
- មានសិទ្ធិក្នុងការទទួលបាន និងត្រួតពិនិត្យរបាយការណ៍សកម្មភាព របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ ឬកំណត់ហេតុផ្សេងៗទៀតរបស់ អ.ជ.ក

ប្រការ ១២: លក្ខណៈវិនិច្ឆ័យបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលមានដូចខាងក្រោម :

- ជាអ្នកដែលមានកិត្តិយស និងសីលធម៌ក្នុងការរស់នៅថ្លៃថ្នូរ និងមានស្មារតីធ្វើការងារជាក្រុម
- មានគោលជំហរខ្ពស់ និងលះបង់ពេលវេលាចូលរួមចំណែកក្នុងកិច្ចការសង្គម សិទ្ធិមនុស្ស និងនីតិរដ្ឋ
- មានចិត្តអំណត់អត់ធន និងសុចរិត ស្មោះត្រង់
- ជាអ្នកមិនប្រព្រឹត្តបទឧក្រិដ្ឋ និងមិនមានការពាក់ព័ន្ធទៅនឹងអំពើពុករលួយ
- មិនលំអៀង និងមិនប្រកាន់បក្សពួក
- ជាអ្នកដែលស្រលាញ់ និងគោរពគោលការណ៍សិទ្ធិមនុស្សជាចំបង ជាពិសេសជនជាតិដើមភាគតិច
- ជាអ្នកមានវិជ្ជាជីវៈឯកទេស ណាមួយដូចជា សេដ្ឋកិច្ច ច្បាប់ សង្គម ហិរញ្ញវត្ថុ គណនេយ្យ ។ល។

ប្រការ១៣: ដំណើរការ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាល

- ការប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាភិបាលនឹងធ្វើឡើងយ៉ាងតិចចំនួន០៣ដង ក្នុង០១ឆ្នាំ ដើម្បីពិនិត្យមើលការអនុវត្តលទ្ធផលការងារឆ្នាំកន្លងទៅ និងដើម្បីស្វែងរកការឯកភាពលើផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំថ្មី
- ប្រធានរបស់ក្រុមប្រឹក្សាភិបាលជាអ្នកកោះប្រជុំ និងសម្របសម្រួលចាត់តាំងឲ្យមានការជួយកត់កំណត់ហេតុនូវរបៀបវារៈប្រជុំ។ ករណីប្រធានអវត្តមានសមាជិកក្រុមប្រឹក្សាដទៃទៀតជាអ្នកដឹកនាំការប្រជុំ។ រាល់ការប្រជុំត្រូវមានការជូនដំណឹងជាមុនយ៉ាងតិច ៥ ទៅ ៧ ថ្ងៃមុនតាមសារអេឡិចត្រូនិក ឬទូរស័ព្ទជាមុន។
- ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបានលុះត្រាតែមានកូរ៉ុមចាប់ពី ៥០%ឡើងទៅ។ បើសិនជា
- មិនគ្រប់កូរ៉ុម កិច្ចប្រជុំចំនួនលើកទី២ នោះប្រធាន និងសមាជិកមានសិទ្ធិក្នុងការសម្រេចចិត្តរៀបចំកិច្ចប្រជុំ

- ក្រុមប្រឹក្សាភិបាលតាមការចាំបាច់។
- ករណីចាំបាច់ក្រុមប្រឹក្សាភិបាលអាចចូលរួមប្រជុំតាមរយៈទូរស័ព្ទ ឬតាមប្រព័ន្ធអេឡិចត្រូនិចឬតាមការផ្ដល់សិទ្ធិជូនសមាជិកដទៃដែលបានចូលរួមប្រជុំ។
- ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលគឺអាចបើកចំហចំពោះបុគ្គលិកផ្សេងទៀតដែលចង់ចូលរួម ឬមានការស្នើសុំរបស់នាយិកា ឬនាយកប្រតិបត្តិ។
- ការប្រជុំវិសាមញ្ញអាចធ្វើទៅបានតាមការចាំបាច់ និងស្នើពីនាយិកា ឬនាយកប្រតិបត្តិ
- រាល់សេចក្ដីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាចយកជាការបានលុះណាតែមានសំឡេងគាំទ្រ ៥០% + ១។

## ជំពូកទី ៦

## អំពីគណៈគ្រប់គ្រង

ប្រការ ១៤: គណៈគ្រប់គ្រង មានសមាសភាព នាយិកាឬនាយកប្រតិបត្តិ ប្រធានកម្មវិធី មន្ត្រីហិរញ្ញវត្ថុ មន្ត្រីរដ្ឋបាល និងប្រធានផ្នែកនីមួយៗ ។

ប្រការ ១៥៖ គណៈគ្រប់គ្រងមានតួនាទីភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវរួមចំពោះមុខ ក្រុមចាស់ទុំជនជាតិដើមភាគតិច និងក្រុមប្រឹក្សាភិបាល
- សម្រេចជ្រើសរើស តែងតាំង និងដាក់វិន័យ បញ្ចប់កិច្ចសន្យាបុគ្គលិក ឬទីប្រឹក្សា
- ជួយការងារក្រុមប្រឹក្សាភិបាល រួមទាំងរបាយការណ៍ និងព្រាងសំណើផ្សេងៗមុនក្រុមប្រឹក្សាភិបាលអនុម័ត
- សម្រេចលើកសំណើថវិកាទៅម្ចាស់ជំនួយ
- ទំនាក់ទំនងជាមួយម្ចាស់ជំនួយ តាមការចាំបាច់
- គ្រប់គ្រងរួមកិច្ចការផ្ទៃក្នុងរបស់ អ.ជ.ក
- ធានានូវកិច្ចប្រតិបត្តិការគម្រោងកម្មវិធី និងការអនុវត្តគោលនយោបាយនានារបស់ អ.ជ.ក
- ព្រាង គោលនយោបាយហិរញ្ញវត្ថុ រដ្ឋបាល ធនធានមនុស្ស ដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ដោះស្រាយបញ្ហាទូទៅរបស់ អ.ជ.ក មុនទៅដល់ក្រុមប្រឹក្សាភិបាល ឬ ក្រុមចាស់ទុំជនជាតិដើមភាគតិច
- ធានាការអនុវត្តគម្រោង និងហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងការទទួលខុសត្រូវ និងការងារភារកិច្ចផ្សេងទៀត តាមការកំណត់របស់ក្រុមប្រឹក្សាភិបាល ឬក្រុមចាស់ទុំជនជាតិដើមភាគតិច
- ប្រជុំជាទៀងទាត់ប្រចាំខែ ឬតាមការចាំបាច់ តាមការកោះអញ្ជើញពីនាយិកា ឬនាយក ឬអ្នកទទួលអាណត្តិ
- កិច្ចប្រជុំគណៈគ្រប់គ្រង អាចយកជាការបាន លុះត្រាតែមានវត្តមានភាគច្រើន២/៣ នៃសមាជិកគណៈគ្រប់គ្រងទាំងមូល រីឯការសម្រេចយកជាបានការលុះត្រាតែមានការគាំទ្រដោយសំឡេង៥០% + ១។

មាត្រា ១៦៖ តួនាទី និងភារកិច្ចសំខាន់ៗរបស់នាយិកា ឬនាយកប្រតិបត្តិ:

- ទទួលខុសត្រូវរួមចំពោះក្រុមប្រឹក្សាភិបាល និងក្រុមចាស់ទុំជនជាតិដើមភាគតិច
- គ្រប់គ្រងដឹកនាំការងារទូទៅ និងទទួលខុសត្រូវរួមរាល់ភារកិច្ចរបស់ អ.ជ.ក
- ចុះហត្ថលេខាលើឯកសារ និងកិច្ចសន្យានានារបស់ អជក
- កោះអញ្ជើញ និងរៀបចំអង្គប្រជុំ

- ធ្វើជាតំណាងឲ្យ អ.ជ.ក ក្នុងការទំនាក់ទំនងខាងក្រៅ ដែលរួមមានទំនាក់ទំនងការងារ និងចូលរួមការប្រជុំផ្សេងៗ
- ជួយពង្រឹងសមត្ថភាពដល់បុគ្គលិក អ.ជ.ក
- សម្របសម្រួលដឹកនាំការធ្វើផែនការគម្រោង
- ត្រួតពិនិត្យការអនុវត្តកម្មវិធី និងផែនការគម្រោង
- ក្នុងករណីអវត្តមានត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរឲ្យទៅសមាជិកណាម្នាក់នៃគណៈគ្រប់គ្រង
- ជាអ្នកសម្រេចជ្រើសតាំង ផ្លាស់ប្តូរ បន្ត ឬបញ្ឈប់កិច្ចសន្យាបុគ្គលិករបស់អ.ជ.ក ទាំងអស់ ដោយមានការពិគ្រោះយោបល់ជាមួយគណៈគ្រប់គ្រង ។
- ស្វែងរកការគាំទ្រជាមូលនិធិ សម្ភារ ឬ បច្ចេកទេស ដើម្បីដំណើរការគម្រោង និងអ.ជ.ក ។

ប្រការ ១៧: តួនាទីភារកិច្ចសំខាន់ៗរបស់ប្រធានគ្រប់គ្រងគម្រោង

- ទទួលខុសត្រូវលើការរៀបចំ និងការបង្កើតយុទ្ធសាស្ត្រគម្រោងរបស់ អជក
- រៀបចំ និងធ្វើផែនការសកម្មភាពគម្រោងសម្រាប់អនុវត្តគម្រោងកម្មវិធីទាំងអស់
- រៀបចំផែនការថវិកា និងផែនការចំណាយរបស់គម្រោងនានា
- ទទួលខុសត្រូវការគ្រប់គ្រងថវិកាចំណាយនៅសហគមន៍មូលដ្ឋាន
- ចូលរួមក្នុងការផ្តួចផ្តើមគំនិតសរសេរគម្រោងស្នើសុំមូលនិធិ
- បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ
- ត្រួតពិនិត្យ និងតាមដាន វាយតម្លៃគម្រោង និងបុគ្គលិក
- ធ្វើទំនាក់ទំនងជាមួយម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធនានា
- ធ្វើរបាយការណ៍សកម្មភាពគម្រោងប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ តាមការចាំបាច់
- រាយការណ៍ជាទៀងទាត់ជូននាយិកាឬនាយកប្រតិបត្តិនូវសកម្មភាពនិងលទ្ធផលគម្រោងសម្រេចបាន ។

ប្រការ១៨: តួនាទីភារកិច្ចរបស់រដ្ឋបាលៈ

- គ្រប់គ្រងការងាររដ្ឋបាល និងឯកសារផ្សេងៗរបស់ អ.ជ.ក
- ធ្វើជាជំនួយការឲ្យនាយិកា នាយក និងកម្មវិធី
- ធ្វើកំណត់ហេតុប្រជុំ និងសេចក្តីសម្រេចចិត្តរបស់អង្គប្រជុំ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់អ.ជ.ក
- រៀបចំលិខិតអញ្ជើញ និងបញ្ជូនតំណាងក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា
- រៀបចំកម្មវិធីនានារបស់ អជក ។

ប្រការ១៩: តួនាទីភារកិច្ចរបស់ហេរញ្ញិក

- គ្រប់គ្រងថវិការបស់ អ.ជ.ក ទៅតាមសេចក្តីសម្រេចចិត្តរបស់គណៈគ្រប់គ្រងនិងក្រុមប្រឹក្សាភិបាល
- រៀបចំ និងគ្រប់គ្រងបញ្ជីចំណូលចំណាយរបស់ អ.ជ.ក

- ដាក់ និង ដកប្រាក់ពីធនាគារតាមការចាំបាច់ដោយមានការឯកភាពពីនាយកឬនាយិកា និងមានហត្ថលេខីជាមួយនាយក ឬនាយិកា ធ្វើរបាយការណ៍តារាងតុល្យការគណនី លទ្ធផលគណនីចំណូល ចំណាយគណនីធនាគារដោយមានសក្ខីប័ត្រ ឬឯកសារពាក់ព័ន្ធផ្សេងៗប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនគណៈគ្រប់គ្រងពិនិត្យ និងសម្រេច ។ គ្រប់របាយការណ៍ហិរញ្ញវត្ថុ ត្រូវចុះហត្ថលេខាដោយហេរញ្ញិក និងនាយិកា ឬនាយកប្រតិបត្តិរបស់ អ.ជ.ក ។
- គ្រប់គ្រងសាច់ប្រាក់ដោយសុវត្ថិភាព
- ជំនួយការនាយិកា ឬនាយកក្នុងការធ្វើផែនការថវិកា
- ទំនាក់ទំនងជាមួយម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធនានា
- ចូលរួមក្នុងការសរសេរគម្រោងស្នើសុំមូលនិធិជាមួយនាយិកា ឬនាយកប្រតិបត្តិ អ.ជ.ក
- សហការជាមួយសវនករពីខាងក្រៅនៅពេលមានបេសកកម្ម សវនកម្មហិរញ្ញវត្ថុជាមួយនាយិកាឬនាយកប្រតិបត្តិរបស់ អ.ជ.ក។

## ជំពូកទី ៧

## អំពីក្រុមចាស់ទុំជនជាតិដើមភាគតិច

ប្រការ២០: ក្រុមចាស់ទុំទាំងអស់របស់ អ.ជ.ក៖

- ជាតំណាងឲ្យចាស់ទុំ ឬសហគមន៍ដើម្បីផ្សារភ្ជាប់កិច្ចការសហគមន៍ជនជាតិដើមភាគតិចជាមួយ អ.ជ.ក
- ឲ្យមានទំនាក់ទំនងល្អជាមួយសហគមន៍ និងដើម្បីពង្រឹងសាមគ្គីភាពឲ្យកាន់តែល្អប្រសើរ
- ផ្តល់ប្រឹក្សាយោបល់ផ្នែកប្រពៃណី ទំនៀមទំលាប់ និងកិច្ចការពាក់ព័ន្ធជាមួយនឹងសហគមន៍ និងចូលរួមក្នុងសកម្មភាព និងកម្មវិធីរបស់ អ.ជ.ក តាមការចាំបាច់ ដូចជាការសិក្សាស្រាវជ្រាវ ការផ្សព្វផ្សាយជាដើម ។

## ជំពូកទី ៨

## អំពីមូលនិធិ និងការគ្រប់គ្រងមូលនិធិ

ប្រការ២១: អ.ជ.ក មានប្រភពចំណូលបានមកពី:

- ការបង់ភាគទានរបស់បុគ្គលិក និងថវិកាទ្រទ្រង់ របស់អ.ជ.ក ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង
- ថ្លៃសេវាកម្មលក់ផលិតផលសិប្បកម្មវត្ថុអនុស្សាវរីយ៍ជនជាតិដើមភាគតិច
- វិភាគទានពីសប្បុរសជនក្នុង ឬក្រៅប្រទេស
- អំណោយជាសម្ភារ ថវិកា របស់បណ្តាអង្គការជាតិ ឬអន្តរជាតិនានា
- អំណោយស្ថាប័នជាតិ ឬអន្តរជាតិផ្សេងៗ ។

ប្រការ២២: រាល់ចំណូលទាំងអស់ ត្រូវរក្សាទុកនៅធនាគារស្របច្បាប់ណាមួយនៃព្រះរាជាណាចក្រកម្ពុជាក្នុងនាម អ.ជ.ក លើកលែងតែថវិកាមួយចំនួនដែលចាំបាច់យកមកចំណាយដែលត្រូវរក្សាទុកប្រអប់សុវត្ថិភាពដែលគ្រប់គ្រង

ដោយហេរញ្ញិក និងមានការយល់ព្រមពីនាយិកា ឬនាយកប្រតិបត្តិ ឬក្រុមប្រឹក្សាភិបាលអាស្រ័យចំនួនថវិកាដែលកំណត់ដោយគោលការណ៍ហិរញ្ញវត្ថុ។

ប្រការ ២៣: ថវិការបស់ អ.ជ.ក នឹងត្រូវប្រើប្រាស់សម្រាប់ចំណាយលើ:

- ការងាររដ្ឋបាល
- ការងារជាបុព្វហេតុបម្រើផលប្រយោជន៍ អ.ជ.ក ដូចជា ផែនការសកម្មភាព ការរៀបចំសិក្ខាសាលា ការ-បណ្តុះ បណ្តាល ទស្សនកិច្ចសិក្សា បេសកកម្មរបស់បុគ្គលិក និងក្រុមប្រឹក្សាភិបាល និងកិច្ចប្រជុំផ្សេងៗ ។
- រាល់ការចំណាយរបស់ អ.ជ.ក ត្រូវមានសក្ខីប័ត្រ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗ ត្រូវមានហត្ថលេខារបស់ហេរញ្ញិក នាយិកា ឬនាយក និងមន្ត្រីកម្មវិធី ។

ប្រការ២៤: ផែនការថវិកាប្រចាំឆ្នាំរបស់ អ.ជ.ក ត្រូវបានរៀបចំឡើងដោយបុគ្គលិកទាំងអស់នៃអ.ជ.ក និងដាក់ជូនក្រុមប្រឹក្សាភិបាលធ្វើការពិនិត្យ និងអនុម័ត។

ប្រការ២៥: ហេរញ្ញិកត្រូវធ្វើរបាយការណ៍រៀងរាល់ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដាក់ជូននាយិកា ឬនាយកប្រតិបត្តិ និងដាក់ជូនគណៈគ្រប់គ្រងពិនិត្យ រួចដាក់ជូនទៅក្រុមប្រឹក្សាភិបាលត្រួតពិនិត្យរបាយការណ៍ប្រចាំឆ្នាំដើម្បីពិនិត្យ និងសម្រេច ។

## ជំពូកទី ៩

## អំពីដំណោះស្រាយ

ប្រការ២៦: រាល់ទំនាស់ផ្ទៃក្នុងរបស់ អ.ជ.ក គឺអាចត្រូវដោះស្រាយដោយគណៈគ្រប់គ្រង ឬ ក្រុមប្រឹក្សាភិបាល ឬ នាយិកា ឬនាយកប្រតិបត្តិ ជាមួយមន្ត្រីពាក់ពន្ធ័អាស្រ័យទៅតាមកម្រិតនៃជម្លោះជាក់ស្តែង។ ករណីវិវាទធ្ងន់ធ្ងររវាងនាយិកា ឬនាយកប្រតិបត្តិ និងក្រុមប្រឹក្សាភិបាល ត្រូវបង្កើតឲ្យមានអ្នកអព្យាក្រិត ដែលរៀបចំឡើងដោយមន្ត្រីប្រធានកម្មវិធី និងបុគ្គលិកផ្សេងទៀត បើចាំបាច់អាចមានការគាំទ្រ និងចូលរួមពីម្ចាស់មូលនិធិ។

## ជំពូកទី ១០

## អំពីការរំសាយ អ.ជ.ក

ប្រការ២៧: ការសម្រេចចិត្តក្នុងការរំសាយ អ.ជ.ក អាចធ្វើទៅបានលុះត្រាតែមានការអនុម័តយល់ព្រមពីអង្គប្រជុំរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល និងបុគ្គលិកមានស្រាប់ចំនួនចាប់ពី៨០% ឡើងទៅដោយសំឡេងគាំទ្រ ៥០% + ១។

ប្រការ២៨: ទ្រព្យសម្បត្តិរបស់អ.ជ.ក ត្រូវបានគ្រប់គ្រងថែទាំមានលក្ខណៈស្តង់ដារ មានបញ្ជីគ្រប់គ្រងសម្ភារផ្ទាល់របស់អ.ជ.ក រួមទាំងសម្ភាររបស់ម្ចាស់ជំនួយ។

ប្រការ២៩: ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ អ.ជ.ក ស្ថិតក្រោមការធ្វើសេចក្តីសម្រេចចិត្តរបស់ គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ដោយត្រូវជម្រះបំណុលស្របច្បាប់រួច ត្រូវប្រគល់ទៅឲ្យអង្គការ ឬសមាគមន ឬសហគមន៍ជនជាតិដើមភាគតិច ឬស្ថាប័នដៃគូដទៃទៀតដែលមានទស្សនៈគោលដៅគោលបំណងប្រហាក់ប្រហែលគ្នាទៅនឹង អ.ជ.ក បានដោយផ្អែកលើមូលដ្ឋាននៃកិច្ចសន្យាជាមួយម្ចាស់ជំនួយ និងស្ថាប័នដៃគូ។

## ជំពូកទី ១១

## អំពីការកែប្រែលក្ខន្តិកៈ

ប្រការ៣០: ការកែប្រែលក្ខន្តិកៈ អាចធ្វើទៅបានតាមរយៈការអនុម័តយល់ព្រមដោយក្រុមប្រឹក្សាភិបាលចាប់ពីចំនួនពី ២/៣ នៃអ្នកចូលរួមឡើងទៅតាមសំណើរបស់គណៈគ្រប់គ្រង ។

## ជំពូកទី ១២

## អវសានប្បញ្ញត្តិ

ប្រការ៣១ : លក្ខន្តិកៈរបស់ អ.ជ.ក ជាច្បាប់កំពូលរបស់ អ.ជ.ក ។

ប្រការ៣២: គោលការណ៍ បទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិនានារបស់ អ.ជ.ក និងបំពេញបន្ថែមសម្រាប់ដំណើរការអនុវត្តផែនការសកម្មភាពរបស់ អ.ជ.ក ។

ប្រការ៣៣: បទប្បញ្ញត្តិទាំងឡាយណារបស់ អ.ជ.ក ដែលមានខ្លឹមសារផ្ទុយពីលក្ខន្តិកៈនេះត្រូវទុកជានិរាករណ៍ ។

ប្រការ៣៤: បន្ទាប់ពីអង្គការជនជាតិដើមភាគតិចកម្ពុជា ទទួលបានការចុះបញ្ជីនៅក្រសួងមហាផ្ទៃ អង្គការត្រូវអនុវត្តសកម្មភាពរបស់ខ្លួនឲ្យបានត្រឹមត្រូវស្របតាមលក្ខន្តិកៈនេះ។ ក្នុងករណីបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈនេះអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចាត់វិធានការតាមនីតិវិធីច្បាប់។

ប្រការ៣៥: លក្ខន្តិកៈនេះមានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

បានតម្កល់ទុកលក្ខន្តិកៈ អង្គការជនជាតិដើម ភាគតិចកម្ពុជា
នៅក្រសួងមហាផ្ទៃ តាមលិខិតលេខ ១៣ [illegible]
ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៤
ភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៤
នាយកដ្ឋានកិច្ចការនយោបាយ
ប្រធាន

ឌី_សុភផាន

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ០២ ឆ្នាំ២០១៤
ជ.គណៈគ្រប់គ្រងអង្គការ
ប្រធាន

# រចនាសម្ព័ន្ធដឹកនាំអង្គការជនជាតិដើមភាគតិច




រាជធានីភ្នំពេញ ថ្ងៃទី..21.... ខែ....02.......ឆ្នាំ ២០១៤

ជ.គណៈគ្រប់គ្រងអង្គការ

ប្រធាន

យុន ម៉ាណោ